# រឿង មនុស្សលោភ



# រឿង មនុស្សលោភ

រៀបរៀងដោយ បណ្ណាល័យអង្គការសន្តិស្ម័គ្រចិត្ត (SVA)

គូររូបដោយ គឹម សុគន្ធ

រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត (SVA)

រឿង **មនុស្សលោភ**



វិចិត្រូបភាពដោយ លោក គីម សុគន្ធ
បោះពុម្ពផ្សាយដោយអង្គការសន្តិស្ម័គ្រចិត្ត



កាលពីព្រេងនាយ មានកុមារីម្នាក់អាយុ ១៤ ឆ្នាំ បានចេញដើរទៅរកដំឡូងនៅក្នុងព្រៃធំ ដែលមានដំបូកមួយមានរូងជ្រៅ។



កុមារីទៅដីកដំឡូងនៅជើងដំបូក ជីកបានបន្ទិចក៏របូតផ្លែចបជ្រុះទៅក្នុងរូងនោះ។ នាងមិនដឹងធ្វើដូចម្តេចក៏ស្រែកប្រកាសថា "លោកអ្នកណាអើយ ជួយយកផ្លែចបឱ្យខ្ញុំបាន ខ្ញុំនឹងសងគុណលោក"។

មួយរំពេចនោះមានខ្លាចាស់ ដ័បៅក្បាលរុយបែងដង្កូវចុះគគ្រិច ចេញមកពីក្នុងព្រៃ ហើយសន្យាថានឹងយកផ្លែចបឱ្យ លុះត្រាតែនាងនោះរកចៃឱ្យខ្លួន។



កុមារីនោះយល់ព្រម ខ្លាក៏យកផ្លែចបបានពីក្នុងរូងឱ្យទៅនាង ហើយនាងក៏យកបន្លាមកឆ្កឹះដង្កូវក្នុងដំបៅក្បាលខ្លា។ ខ្លាចេះតែសួរនាងថា "នាង! ដំបៅតាស្អុយ ឬក្រអូប?"។ ដំបៅនេះស្អុយណាស់ ប៉ុន្តែ នាងចេះតែឆ្លើយប្រាប់ទៅវិញថា "ក្រអូបណាស់លោកតា"។



លុះឆ្អឹះដង្កូវអស់ទៅ ខ្លាបាត់ឈឺ បាត់រមាស់ ហើយប្រាប់ទៅនាងថា "ចៅយកជាលមួយមក តានឹងដាក់ជំឡូងឱ្យ"។ នាងនោះយកជាលមួយមកឱ្យខ្លា ខ្លាដាក់សុទ្ធតែមាសប្រាក់ពេញជាលចងមាត់ជាលជាប់ ដោយផ្ដាំថា "ពេលទៅដល់ផ្ទះ ហៅបងប្អូនមកជុំបិទទ្វារឱ្យជិតសឹមបើក"។



នាងនោះលាខ្លា ដើរទៅដល់ផ្ទះ ហៅបងប្អូនមកជុំ រួចក៏បើកជាល។ ដល់បើកមើលទៅបានសុទ្ធតែមាស និង ប្រាក់ ហើយក៏ចែកគ្នាទៅ។



លុះយូរបន្តិច រឿងនោះដឹងដល់ស្រីឯទៀត ដែលមានកូនក្រមុំ ក៏ប្រើឱ្យកូនខ្លួនទៅជីកដំឡូង ដើម្បីជួបខ្លា ដោយធ្វើឱ្យដូចនាងមុននឹងបានមាសចែកគ្នា។



លុះបានទៅដល់ កូនស្រីនោះបានជួបនឹងខ្លា ក៏ធ្វើជាជ្រុះចប ហើយនិយាយថា "លោកអ្នកណាយកចបឱ្យខ្ញុំបាន ខ្ញុំនឹងដឹងគុណលោក"។ ខ្លាឮហើយក៏យកមកឱ្យ រួចឱ្យនាងនោះចាប់ដង្កូវឱ្យ។



ខ្លាសួរដូចពីមុនថា "នាង! ដំបៅតាស្អុយ ឬ ក្រអូប?" នាងឆ្លើយថា "ស្អុយណាស់"។



ខ្លាព្នដូច្នោះ ក៏បង្គាប់ឱ្យនាងយកជាលមកឱ្យខ្លួន ហើយចាប់សុទ្ធតែពស់វែកដាក់ពេញជាល រួចប្រាប់ថា "នាងយកទៅផ្ទះ ហៅបងប្អូនមកជុំ បិទទ្វារឱ្យជិតសឹមបើក"។



នាងនោះទៅដល់ផ្ទះ ហើយប្រាប់ម្ដាយ ម្ដាយអរណាស់ ឱ្យបងប្អូនមកជួបជុំ រួចបិទទ្វារ ហើយក៏បើកជាលមើល។ ពស់វែកចេញមកចឹកមនុស្សទាំងនោះស្លាប់អស់ទៅ៕

ចប់